


# របាយការណ៍ប្រចាំឆ្នាំ ២០២១

*លទ្ធផលសម្រេចបានសំខាន់ៗ*

ជីវិតធម្មជាតិនៅកម្ពុជា
NatureLife Cambodia

# មាតិកា

១. អង្គការជីវិតធម្មជាតិនៅកម្ពុជា៖ ចក្ខុវិស័យ និងបេសកកម្ម ..... 3
២. លទ្ធផលសម្រេចបានប្រចាំឆ្នាំ ២០២១ ..... 5
២.១ ទប់ស្កាត់ការផុតពូជ ..... 5
២.២ អភិរក្សទីជម្រក ..... 8
២.៣ អភិរក្សសត្វស្លាបទេសន្តរប្រវេសន៍ ..... 14
២.៤ លើកកម្ពស់ជីវភាព និងបង្កើនការចូលរួមពីប្រជាមូលដ្ឋាន ..... 15
២.៥ កសាងសមត្ថភាព ..... 20
៣. របាយការណ៍ហិរញ្ញវត្ថុ ..... 22
៤. ដៃគូ និងម្ចាស់ជំនួយ ..... 23



@Thol Sovannarith/BirdLife in Cambodia

## ១. អង្គការជីវិតធម្មជាតិនៅកម្ពុជា៖ ចក្ខុវិស័យ និងបេសកកម្ម

អង្គការជីវិតធម្មជាតិនៅកម្ពុជាគឺជាដៃគូផ្លូវការរបស់អង្គការជីវិតសត្វស្លាបអន្តរជាតិ( BirdLife International )តែមួយគត់នៅក្នុងប្រទេសកម្ពុជា។ ក្រុមប្រឹក្សាភិបាលសកលរបស់អង្គការជីវិតសត្វស្លាបអន្តរជាតិបានទទួលស្គាល់អង្គការជីវិតធម្មជាតិនៅកម្ពុជាគឺជាដៃគូផ្លូវការប្រចាំកម្ពុជានាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២០ព្រមទាំងចុះកិច្ចព្រមព្រៀងរវាងក្រុមប្រឹក្សាភិបាលរបស់អង្គការទាំងពីរផងដែរ។

អង្គការជីវិតធម្មជាតិនៅកម្ពុជា គឺជាអង្គការក្នុងស្រុកធ្វើការផ្នែកអភិរក្សដែលបានចុះបញ្ជីជាផ្លូវការក្នុងក្រសួងមហាផ្ទៃក្នុងខែកុម្ភៈ ឆ្នាំ២០១៧។ អង្គការជីវិតធម្មជាតិនៅកម្ពុជា គឺជាអង្គការដែលមិនស្វែងរកប្រាក់កម្រៃជាឯកជន អព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ និងមិនផ្តល់មធ្យោបាយជាសម្ភារ ហិរញ្ញវត្ថុ ឬធនធានមនុស្សដើម្បីគាំទ្រគណបក្សនយោបាយ ឬមនោគមវិជ្ជាណាមួយឡើយ។ អង្គការនេះត្រូវបានបង្កើតឡើងដោយមានការគាំទ្រយ៉ាងពេញទំហឹងពីអង្គការជីវិតសត្វស្លាបអន្តរជាតិក្រោមជំនួយផ្នែកហិរញ្ញវត្ថុពី មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីទទួលរងការគំរាមកំហែង (CEPF) តាមរយៈអង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN)។ អង្គការជីវិតធម្មជាតិនៅកម្ពុជាត្រូវបានបង្កើតឡើងដោយស្ថាបនិក ១២នាក់ ដែលក្នុងនោះ១០នាក់ គឺជាបុគ្គលិកស្នូលរបស់អង្គការជីវិតសត្វស្លាបអន្តរជាតិប្រចាំកម្ពុជា។ ការផ្តួចផ្តើមបង្កើតនេះ គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រអន្តរកាលនៃការកសាងសមត្ថភាពអង្គការក្នុងស្រុករបស់អង្គការជីវិតសត្វស្លាបអន្តរជាតិដើម្បីអាចចាប់ជាដៃគូនាពេលអនាគត (គិតមកដល់បច្ចុប្បន្នអង្គការជីវិតសត្វស្លាបអន្តរជាតិមានដៃគូចំនួន ១២១ ក្នុងបណ្តាប្រទេសនានាជុំវិញពិភពលោក)។ សមាជិកស្ថាបនិកទាំង១២នាក់ របស់អង្គការជីវិតធម្មជាតិកម្ពុជា ជឿជាក់ថា បុគ្គលិកកម្ពុជានឹងអាចអនុវត្តន៍បេសកកម្មរបស់អង្គការជីវិតសត្វស្លាបអន្តរជាតិនេះបាន។




*កិច្ចប្រជុំនាយកអង្គការជីវិតធម្មជាតិនៅកម្ពុជាជាមួយគណៈគ្រប់គ្រងរបស់អង្គការជីវិតសត្វស្លាបអន្តរជាតិ*

អង្គការជីវិតធម្មជាតិនៅកម្ពុជាមានចក្ខុវិស័យ បេសកកម្ម និងកម្មវិធីដូចខាងក្រោម៖

- **ចក្ខុវិស័យ** ៖ ទាំងអស់គ្នាដើម្បីរស់នៅប្រកបដោយសុខដុមរមនារវាងមនុស្ស និងធម្មជាតិ។
- **បេសកកម្ម** ៖ ធ្វើការអភិរក្សជីវៈចម្រុះតាមរយៈការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាពដើម្បីជាប្រយោជន៍របស់យើងទាំងអស់គ្នា។

និងបែងចែកជា**កម្មវិធីចំនួន៥**៖

១. ទប់ស្កាត់ការផុតពូជ

២. អភិរក្សទីជម្រក

៣. អភិរក្សសត្វស្លាបទេសន្តរប្រវេសន៍

៤. លើកកម្ពស់ជីវភាព និងបង្កើនការចូលរួមពីប្រជាមូលដ្ឋាន

៥. កសាងសមត្ថភាព

ជីវិតធម្មជាតិនៅកម្ពុជា
NatureLife Cambodia

ទប់ស្កាត់ការផុតពូជ



អភិរក្សទីជម្រក



អភិរក្សសត្វស្លាបទេសន្តរប្រវេសន៍



ការលើកកម្ពស់ជីវភាពប្រជាមូលដ្ឋាន



ការបង្កើនសមត្ថភាព



# ២. លទ្ធផលសម្រេចបានប្រចាំឆ្នាំ ២០២១

## ២.១ ទប់ស្កាត់ការផុតពូជ

### ដែនជម្រកសត្វព្រៃលំផាត់

- ការស្វែងរក និងអង្កេតតាមដានសំបុកសត្វត្រយងយក្ស គឺជាការងារអាទិភាពមួយ។ សកម្មភាពនេះធ្វើឡើងចាប់ពីខែឧសភាដល់ខែតុលា។ ដើម្បីស្វែងរកសំបុកសត្វស្លាបប្រភេទនេះ ក្រុមការងារអង្គការជីវិតធម្មជាតិនៅកម្ពុជាបានដើររុករកទីតាំងជាច្រើននៅខាងក្នុង និងជុំវិញដែនជម្រកសត្វព្រៃ។ ជាលទ្ធផល សំបុកសត្វត្រយងយក្សចំនួន១១ ត្រូវបានរកឃើញ និងកត់ត្រាទុក។ កូនបក្សីចំនួន ១១ក្បាល ញាស់ដោយជោគជ័យចេញពីសំបុកចំនួន៨ ដែលក្រុមការងារយើងបានរកឃើញ។ ចំណែកឯកូនបក្សីនៅក្នុងសំបុក៣ ផ្សេងទៀតញាស់មិនបានជោគជ័យដោយសារមានការរំខាន និងការប្រមូលកូនពីសកម្មភាពមនុស្ស។
- ការស្វែងរក និងអង្កេតតាមដានសំបុកសត្វត្រយងចង្កំកស បានចាប់ផ្តើមពីខែធ្នូ ឆ្នាំ ២០២០ ដល់ខែមេសា ឆ្នាំ ២០២១។ ជាលទ្ធផលសំបុកត្រយងចង្កំកសចំនួន១០ត្រូវបានរកឃើញ។ កូនត្រយងចង្កំកសចំនួន៩ក្បាល បានញាស់ដោយជោគជ័យចេញពីសំបុកចំនួន៦ ខណៈដែលសំបុកផ្សេងទៀតមិនបានជោគជ័យ។ កូនបក្សីក្នុងសំបុកដទៃទៀតញាស់មិនបានសម្រេចដោយសារមានការរំខានពីមនុស្ស ភ្លើងឆេះព្រៃ និងសត្វព្រៃដទៃទៀត។
- ការអង្កេតតាមដានត្រពាំងក្នុងឆ្នាំ ២០២០-២០២១ ត្រូវបានធ្វើឡើងចាប់ពីខែធ្នូ ឆ្នាំ ២០២០ ដល់ខែមេសា ឆ្នាំ ២០២១។ ត្រពាំងដែលត្រូវបានស្តារឡើងវិញចំនួន៧ និង ត្រពាំងមិនទាន់ស្តារឡើងវិញចំនួន៩ ត្រូវបានអង្កេតតាមដានពីរដងក្នុងមួយខែ នៅពាក់កណ្តាល និងចុងខែ រៀងរាល់ខែ រហូតដល់ទឹករីងស្ងួតអស់ពីត្រពាំង។ ក្រោយពីត្រួតពិនិត្យអស់រយៈពេល៥ខែ លទ្ធផលបានបង្ហាញថា ត្រពាំងដែលមិនត្រូវបានស្តារឡើងវិញបានរីងស្ងួតអស់មុនត្រពាំងដែលបានត្រូវបានស្តារឡើងវិញរួច ។ ទោះជាយ៉ាងណាក៏ដោយត្រពាំងភាគច្រើនបានរីងស្ងួតអស់ទាំងស្រុងនៅកំឡុងខែមេសា។ លើសពីនេះទៀត ប្រភេទសត្វសំខាន់ៗត្រូវបានកត់ត្រាក្នុងអំឡុងពេលអង្កេតតាមដានរួមមាន សត្វត្រយងយក្ស សត្វត្រយងចង្កំកស ត្រដក់តូច និង សត្វកុកពាក់អំបោះ ។ សត្វស្លាបទាំងនេះភាគច្រើនត្រូវបានក្រុមការងារអង្គការជីវិតធម្មជាតិកត់ត្រាបាន នៅត្រពាំងដែលមិនទាន់ត្រូវបានស្តារឡើងវិញ។ លើសពីនេះ ក្រុមការងារអង្កេតជីវចម្រុះរបស់យើង បានកត់ត្រាការតាមដាន និងការមើលឃើញប្រភេទសត្វសំខាន់ៗ ដែលបានប្រើប្រាស់ត្រពាំងដែលបានស្តារឡើងវិញរួចក្នុងខែនេះ ដោយមិនរាប់បញ្ចូលកាលវិភាគអង្កេតតាមដានប្រចាំខែ។
- ជំរឿនសត្វត្រយងចង្កំកស ក៏ជាការងារអាទិភាពមួយក្នុងរដូវវស្សាដែរ។ ជំរឿននេះត្រូវបានធ្វើឡើងម្តងក្នុងមួយខែ ចាប់ពីខែកក្កដា ដល់ខែតុលា។ ក្នុងកំឡុងរដូវកាលជំរឿននេះ ក្រុមការងារយើងបានស្ទះស្វែងខិតខំប្រឹងដើម្បីស្វែងរកជម្រករបស់សត្វត្រយងចង្កំកស។ ជាលទ្ធផល មានតែបក្សីចំនួន៥ក្បាល ប៉ុណ្ណោះដែលក្រុមការងារកត់ត្រាបាន។ សត្វត្រយងចង្កំកស ៥ក្បាល ជាចំនួនច្រើនបំផុតដែលកត់ត្រាបានចាប់ពីខែកក្កដា ដល់ខែកញ្ញា។ ចំនួនទាបបំផុតនៃសត្វត្រយងចង្កំកស ដែលកត់ត្រាបានគឺ៣ក្បាល ក្នុងខែតុលា។ ទីតាំងជម្រកស្រែតាម៉ុក ជាទីតាំងដែលមានចំនួនសត្វត្រយងចង្កំកសច្រើនជាងគេ ( ចំនួន៥ក្បាល ) ក្នុងចំណោមទីតាំងជម្រកផ្សេងទៀតដែលក្រុមការងារយើងបានធ្វើការអង្កេតតាមដាន។



សំបុកត្រយងយក្សនៅដែនជម្រកសត្វព្រៃលំផាត់



សំបុកត្រយងចង្កំកសនៅដែនជម្រកសត្វព្រៃលំផាត់

## ការអភិរក្សសត្វត្មាតកម្ពុជា

- អង្គការជីវិតធម្មជាតិនៅកម្ពុជាត្រូវបានគាំទ្រអោយបម្រើតួនាទីជាលេខាដ្ឋានសម្របសម្រួលនៃក្រុមការងារអភិរក្សសត្វត្មាតកម្ពុជាជំនួយអង្គការជីវិតសត្វស្លាបអន្តរជាតិកម្មវិធីប្រចាំកម្ពុជា។ នៅក្នុងបរិបទកូវីដ១៩ កិច្ចប្រជុំរបស់ការងារនេះត្រូវបានសម្របសម្រួលនិងរៀបចំតាមប្រព័ន្ធzoom.
- អង្គការជីវិតធម្មជាតិនៅកម្ពុជាត្រូវបានគាំទ្រអោយក្លាយជាដៃគូនៃបណ្តាញអភិរក្សសត្វត្មាតប្រចាំអាស៊ីជំនួយអង្គការជីវិតសត្វស្លាបអន្តរជាតិកម្មវិធីប្រចាំកម្ពុជា។
- ទិវាយល់ដឹងពីសត្វត្មាតអន្តរជាតិនាខែកញ្ញា ឆ្នាំ២០២១ត្រូវបានរៀបចំតាមប្រព័ន្ធZOOMដែលមានអ្នកចូលរួមប្រម៉ាណជា១៣០នាក់។ ដោយឯកឧត្តម នេត្រ ភក្ត្រា(រដ្ឋលេខាធិការក្រសួងបរិស្ថាន)ជាអធិបតេយ្យ កម្មវិធីរៀបចំក្នុងគោលបំណងបង្កើនការយល់ដឹងពីស្ថានភាពសត្វត្មាតនៅកម្ពុជា តួនាទីសត្វត្មាតក្នុងប្រព័ន្ធអេកូឡូស៊ី និងផលប៉ះពាល់នៃការបំពុលលើសត្វត្មាត។
- ពិធីសារឆ្លើយតបការពុលត្រូវបានបញ្ចប់ និងគាំទ្រដោយសមាជិក ក្រុមការងារអភិរក្សសត្វត្មាតកម្ពុជា ។ ពិធីសារនេះត្រូវបានបែងចែកទៅជាសកម្មភាពសំខាន់ពីរ ១) ពិធីសារឆ្លើយតបនឹងការបំពុលឬកំចាត់ការបំពុល (វានឹងត្រូវបានប្រើនៅពេលដែលសារជាតុពុលត្រូវបានរកឃើញនៅក្នុងបរិស្ថាន និងនៅពេលដែលចាំបាច់នៅក្នុងការបន្សាបជាតិពុល) និង ២) ពិធីសារសម្រាប់គ្រប់គ្រងសត្វមានជីវិត (វានឹងត្រូវបានប្រើដើម្បីធ្វើអន្តរាគមន៍ក្នុងករណីជួបប្រទះជាមួយសត្វមានជីវិតដែលកំពុងរងការពុលនិងមានឧប្បត្តិហេតុផ្ទុះជំងឺ)។ នៅក្នុងត្រីមាសទី២ឆ្នាំ២០២២ ដោយមានការគាំទ្រផ្នែកថវិកាពីមូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីទទួលរងការគំរាមកំហែង អង្គការជីវិតធម្មជាតិនៅកម្ពុជានឹងរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាដើម្បីណែនាំពិធីសារនេះដល់ក្រុមការងារនៅក្នុងខេត្តទាំង៣ ដើម្បីធានាថាពួកគេនឹងប្រើប្រាស់វានៅពេលដែលការបំពុលកើតឡើងនៅទីតាំងការងាររបស់ពួកគេ។
- ការប្រមូលទិន្នន័យអំពី ថ្នាំឌីក្លូហ្វីណាក (Diclofenac) និង ថ្នាំអិនសេដន៍ (NSAIDs) នៅទីតាំងសំខាន់ៗទាំង ៤ ត្រូវបានបញ្ចប់រួចរាល់។ យើងបានសម្ភាសន៍គ្រួសារចិញ្ចឹមសត្វចំនួន ៤៩៦ កន្លែង ឱសថស្ថានសត្វចំនួន ៣៥កន្លែង និងពេទ្យសត្វចំនួន ២៣ នាក់។ របាយការណ៍នឹងត្រូវបានរៀបរៀងនៅកំឡុងត្រីមាសទីមួយ នៃឆ្នាំ ២០២២។
- លទ្ធផលនៃ ការអង្កេតតាមដានការប្រើប្រាស់ថ្នាំឌីក្លូហ្វីណាក (Diclofenac) និង ថ្នាំអិនសេដន៍ (NSAIDs) នៅចុងខែធ្នូ ឆ្នាំ ២០២១នៅខេត្តចំនួនបី (រតនគិរី ស្ទឹងត្រែង និងព្រះវិហារ) បង្ហាញថា គ្មានថ្នាំពេទ្យសត្វប្រភេទឌីក្លូហ្វីណាក (Diclofenac) មានលក់នៅលើទីផ្សារ ដែលជាដំណឹងល្អសម្រាប់សត្វត្មាត។




កិច្ចប្រជុំក្រុមការងារអភិរក្សសត្វត្មាតកម្ពុជា

## ២.២ អភិរក្សទីជម្រក

### តំបន់ការពារទេសភាពបឹងព្រែកល្ពៅ

នៅតំបន់នេះអង្គការជីវិតធម្មជាតិនៅកម្ពុជាទទួលបន្ទុកអប់រំប្រជាពលរដ្ឋក្នុងមូលដ្ឋានឱ្យចូលរួមក្នុងការអភិរក្សជម្រក ដែលជាសមិទ្ធិផលសំខាន់ៗមួយចំនួនរួមមាន៖

- ការរួមបញ្ចូលមុខវិជ្ជាការអប់រំបរិស្ថាន និងការអភិរក្សសត្វ ជាមួយនឹងកាលវិភាគសាលាគោលដៅចំនួន៣។ គ្រូបង្រៀនចំនួន១៤នាក់ មកពីសាលាបឋមសិក្សាទាំង៣ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាលតាមអ៊ីនធឺណិតលើមេរៀនចំនួន៤ (១)តំបន់ដីសើមការពារទេសភាព ២)សត្វក្រៀល ៣)ជីវចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ៤)ការបំពុលបរិស្ថាន)។
- ការបញ្ចប់ការបង្រៀនស្តីពីការអប់រំបរិស្ថាន និងការអភិរក្សសត្វក្រៀលចំនួន៥មេរៀនក្នុងចំណោម១០មេរៀន នៅសាលាបឋមសិក្សាបន្ទាយជី ជាមួយសាលាបឋមសិក្សាសង្កាត់មានជ័យ និងសាលាបឋមសិក្សាគ្គុលជ្រុំ បានបញ្ចប់ត្រឹមតែ៣មេរៀនប៉ុណ្ណោះ។
- ការរៀបចំការប្រឡងជាមួយសិស្សមកពីសាលាបឋមសិក្សាទាំងបី ដើម្បីវាយតម្លៃចំណេះដឹងរបស់សិស្សទាំងអស់ទាក់ទងនឹងការអប់រំផ្នែកបរិស្ថាន។ សិស្សដែលបានប្រឡងជាប់ជាមួយនឹងពិន្ទុខ្ពស់បំផុតចំនួន៧៦នាក់ទទួលបានរង្វាន់។

- ការផ្តល់សម្ភារៈឧបទេស (សៀវភៅគ្រូ ១០ក្បាល សៀវភៅសិស្ស ៩៥ក្បាល សៀវភៅរូបភាព ២៥ក្បាល ប៊ិច ក្រដាស A4 ប្រតិទិន និងសម្ភារៈផ្សេងទៀត) សម្រាប់បង្រៀនដល់សាលាគោលដៅទាំង៣ នៃគម្រោង ការអភិរក្សសត្វក្រៀលនិង ការអប់រំចំណេះដឹងបរិស្ថាននៅតំបន់ការពារទេសភាពបឹងព្រែកល្ពៅ។
- ផ្លាកសញ្ញាចំនួន៣ ត្រូវបានតំឡើងរួចរាល់ ដើម្បីលើកកម្ពស់ការអភិរក្សសត្វក្រៀល ដោយមានសារលើកទឹកចិត្តដល់សហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងសំណល់កសិកម្ម នៅវត្តសង្គមមានជ័យ ភូមិបន្ទាយស្បូវ និងសាលាបឋមសិក្សាបន្ទាយធ្លក។
- ផ្លាកសញ្ញាស្វាគមន៍ចំនួនបីត្រូវបានតំឡើងរួចរាល់នៅសង្កាត់បូរីជលសា និងស្រុកកោះអណ្តែត ដើម្បីអោយសាធារណជនបានដឹងអំពីទីតាំងតំបន់ការពារទេសភាពបឹងព្រែកល្បៅ។
- រូបថតសត្វក្រៀល ចំនួន១០សន្លឹក ត្រូវបានប្រគល់ជូនមន្ទីរបរិស្ថានខេត្តតាកែវ ស្រុកកោះអណ្តែត និងស្រុកបុរីជលសា ឃុំចំនួន៦ ជុំវិញបឹងព្រែកល្ពៅ។ គោលបំណងនៃសកម្មភាពនេះគឺដើម្បីរំលឹកអំពីវត្តមាននៃសត្វក្រៀលដែលជាប្រភេទសត្វដែលរងការគំរាមកំហែងជាសកលស្ថិតនៅក្នុង បឹងព្រែកល្ពៅ។ សូមថែរក្សាដីសើមនេះផង!
- ការចាក់ផ្សាយសារជាសំឡេងតាមទូរស័ព្ទ ដើម្បីជូនដំណឹងអំពីផលប៉ះពាល់អវិជ្ជមានពីការទន្ទ្រានយកដី ការដុតព្រៃលិចទឹក ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ការបំពុលសត្វព្រៃ និងការប្រមូលពងសត្វស្លាបដល់សហគមន៍មូលដ្ឋានជុំវិញ បឹងព្រែកល្ពៅ ជាមួយនឹងការចែកប្រតិទិន សត្វក្រៀលត្រូវបានបញ្ចប់ ។ ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ យើងក៏បានចែកសម្ភារៈដូចជា ម៉ាស និងអាល់កុល ដល់អាជ្ញាធរមូលដ្ឋាន នៅក្នុងភូមិក្តុលជ្រុំ ភូមិសង្គមមានជ័យ ភូមិបន្ទាយស្លែក ភូមិចំបក់ឯម ភូមិប្រឡាយមាន ភូមិដើមក្រូច ភូមិបន្ទាយធ្លាយ ភូមិដីលើក និងភូមិកែវកំភ្លេង។



ការផ្សព្វផ្សាយអំពីផលប៉ះពាល់អវិជ្ជមានដល់តំបន់ការពារទេសភាពបឹងព្រែកល្ពៅ

## តំបន់ការពារទេសភាពអន្លង់ព្រីង



ការគ្រប់គ្រងកាកសំណល់គ្រោះថ្នាក់កសិកម្មនៅក្នុងភូមិគោលដៅជុំវិញតំបន់ការពារទេសភាពអន្លង់ព្រីង

នៅតំបន់នេះ អង្គការជីវិតធម្មជាតិនៅកម្ពុជា ទទួលបន្ទុកអប់រំប្រជាពលរដ្ឋក្នុងមូលដ្ឋានឱ្យចូលរួមក្នុងការអភិរក្សជម្រក ដែលជាសមិទ្ធិផលសំខាន់ៗមួយចំនួនរួមមាន៖

- ការចាក់ផ្សាយសារជាសំឡេងតាមទូរស័ព្ទត្រូវបានធ្វើឡើង ដើម្បីលើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់នៃការប្រើប្រាស់សារជាតុគីមីគ្រោះថ្នាក់កសិកម្ម និងកាកសំណល់របស់វាដល់សហគមន៍មូលដ្ឋានជុំវិញតំបន់ការពារ និងលើកទឹកចិត្តប្រជាសហគមន៍ឱ្យរក្សាទុកកាកសំណល់កសិកម្មនៅក្នុងធុងជុំវិញតំបន់ការពារអន្លង់ព្រីង។ មានមនុស្សជាង ១០០០នាក់ដែលបានឮសារជាសំឡេង នេះ។
- កិច្ចប្រជុំតូចមួយដើម្បីលើកកម្ពស់ការយល់ដឹងក៏ត្រូវបានធ្វើឡើងនៅក្នុងភូមិជុំវិញតំបន់ការពារទេសភាពអន្លង់ព្រីង ដោយមានការសហការជាមួយមេភូមិ។ សារសំខាន់នៃកិច្ចប្រជុំនេះគឺផ្តោតអំពីផលប៉ះពាល់នៃកាកសំណល់កសិកម្ម បញ្ហានៃការប្រើប្រាស់គីមីកសិកម្មលើសុខភាពសាធារណៈ និងប្រព័ន្ធអេកូឡូស៊ីដីសើម និងវិធីសាស្ត្រការពារនៅពេលប្រើប្រាស់សារជាតុគីមីគ្រោះថ្នាក់នេះ។ ចំនួនអ្នកចូលរួមសរុបក្នុងមួយកិច្ចប្រជុំមានប្រហែលពី ១០ ទៅ ១៥នាក់
- ធុងសំរាមចំនួន៧ ត្រូវបានផ្តល់ជូនសាលាបឋមសិក្សាចំនួន៦ និងស្នាក់ការតំបន់ការពារទេសភាពអន្លង់ព្រីង។ ធុងសំរាមនេះមានគោលបំណងធ្វើឱ្យប្រជាពលរដ្ឋសិស្សានុសិស្សញែកសំរាម ក្នុងការគ្រប់គ្រងកាកសំណល់ជីវិតប្រចាំថ្ងៃ។

- ពង្រីកការគ្រប់គ្រងកាកសំណល់គ្រោះថ្នាក់កសិកម្មនៅក្នុងភូមិគោលដៅជុំវិញតំបន់ការពារទេសភាពអន្លង់ព្រីង។ នៅឆ្នាំ២០២១ ប្រអប់ស្តុកទុកសម្រាប់កាកសំណល់គ្រោះថ្នាក់កសិកម្ម ចំនួន១៦ ត្រូវបានតំឡើង ដើម្បីជំរុញឲ្យសហគមន៍មូលដ្ឋានដាក់កាកសំណល់គ្រោះថ្នាក់ ក្នុងគោលបំណងកាត់បន្ថយផលប៉ះពាល់នៃកាកសំណល់ លើប្រព័ន្ធអេកូឡូស៊ីតំបន់ដីសើមអន្លង់ព្រីង។សកម្មភាពនេះជាផ្នែកមួយនៃការពង្រីកគម្រោងនេះ។
- កាកសំណល់គ្រោះថ្នាក់កសិកម្មត្រូវបានប្រមូលពីប្រអប់ស្តុកទុក និងវាលស្រែជុំវិញអន្លង់ព្រីងចំនួន៣ដង និងដឹកជញ្ជូនទៅរក្សាទុកនៅទីទួលសុវត្ថិភាពនៅតំបន់ចាក់សំរាមកំពង់ត្រាច។ បរិមាណសំណល់គ្រោះថ្នាក់សរុបមាន ៦១៧ដប/ថង់ ពីភូមិកោះឈុំកា ២១២ដប/ថង់ ពីភូមិកោះត្នោត ១៩០ដប/ថង់ និងភូមិច្រេស ៣៣២ដប/ថង់។




កាកសំណល់គ្រោះថ្នាក់កសិកម្មត្រូវបានប្រមូលនិងគ្រប់គ្រងនៅតំបន់ការពារទេសភាពអន្លង់ព្រីង

## តំបន់រ៉ាមសារស្ទឹងសែន

- **ការរៀបចំផែនការកំណត់និងគ្រប់គ្រងតំបន់៖** អង្គការជីវិតធម្មជាតិនៅកម្ពុជាបានចូលរួមជាទៀងទាត់នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ខេត្តស្តីពីការកំណត់តំបន់ និងផែនការគ្រប់គ្រងការអភិវឌ្ឍន៍ទីតាំងស្ទឹងសែនរ៉ាមសារ។

- **ការពង្រឹងសមត្ថភាពដល់មន្ត្រីឧទ្យានុរក្សរបស់រដ្ឋាភិបាលៈ** អង្គការជីវិតធម្មជាតិនៅកម្ពុជាអាចផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសជាបន្តបន្ទាប់ដល់មន្ត្រីអនុរក្សរដ្ឋាភិបាលនៅរមណីយដ្ឋានស្ទឹងសែនរ៉ាមសារ ដែលភាគច្រើនផ្តោតលើការកែលម្អការគ្រប់គ្រងធនធានធម្មជាតិតាមរយៈការល្បាតប្រចាំខែរបស់ពួកគេលើការអង្កេតតាមដានជីវចម្រុះ និងការអនុវត្តច្បាប់។
- **កម្មវិធីស្មាតម៉ូបាល (SMART Mobile)៖** អង្គការជីវិតធម្មជាតិនៅកម្ពុជាបានចាប់ផ្តើមផ្តល់វគ្គបណ្តុះបណ្តាលស្តីពី កម្មវិធីស្មាតម៉ូបាល SMART Mobile នៅក្នុងខែឧសភា ឆ្នាំ ២០២១ ដើម្បីគាំទ្រដល់ការល្បាតអនុវត្តច្បាប់ និងបង្កើនប្រសិទ្ធភាពនៃការអង្កេតតាមដានជីវៈចម្រុះក្នុងតំបន់រ៉ាមសារស្ទឹងសែន ក្នុងនោះទូរស័ព្ទទំនើបចំនួន ១គ្រឿងត្រូវបានចែកជូនមន្ត្រីឧទ្យានុរក្សបន្ទាប់ពីវគ្គបណ្តុះបណ្តាល (១គ្រឿង សម្រាប់ទីស្នាក់ការផាត់សណ្តាយ និង១គ្រឿងសម្រាប់ទីស្នាក់ការបឹងធំ)។ ជាលទ្ធផល មន្ត្រីឧទ្យានុរក្សចំនួន ១៣នាក់នៅតំបន់រ៉ាមសារស្ទឹងសែនអាចអនុវត្តប្រើប្រាស់កម្មវិធីស្មាតម៉ូបាល ក្នុងការល្បាតប្រចាំខែរបស់ពួកគេ ហើយទិន្នន័យរបស់ កម្មវិធីស្មាតម៉ូបាល (SMART) ត្រូវបានប្រើប្រាស់នៅក្នុងរបាយការណ៍ប្រចាំខែនៅក្នុងខែបន្ទាប់។
- **ការឧបត្ថម្ភនិងគាំទ្រការល្បាតប្រចាំខែៈ** អង្គការជីវិតធម្មជាតិនៅកម្ពុជាគាំទ្រលើការចំណាយប្រចាំខែលើសកម្មភាពល្បាត (សាំង ប្រាក់ឧបត្ថម្ភល្បាត និងថ្លៃធ្វើដំណើរផ្សេងទៀត) និងសម្ភារៈចាំបាច់ ដូចជា ទូក កាមេរ៉ា ជីភីអេស(GPS) កែវយឹត ទូរស័ព្ទដៃ និងឧបករណ៍ផ្សេងៗទៀត ដល់មន្ត្រីឧទ្យានុរក្សនៅតំបន់រ៉ាមសារស្ទឹងសែន។ ជាមួយនឹងការគាំទ្រនេះ ក្នុងមួយឆ្នាំជាប់ៗគ្នាចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២១ ក្រុមមន្ត្រីឧទ្យានុរក្សបានធ្វើការល្បាតប្រចាំខែជាទៀងទាត់ ដោយទទួលបានលទ្ធផលដូចខាងក្រោមៈ

  -ចំនួនមន្ត្រីឧទ្យានុរក្សៈ ១៣នាក់
  -ចំនួនល្បាតៈ ៣៩លើក
  - ចម្ងាយល្បាតៈ ៤២៣៤ គីឡូម៉ែត
  -ស្នាក់ចាប់បានករណីខុសច្បាប់ : ២៣ករណី
  - ប្រភេទសត្វដែលបានកត់ត្រាៈ បក្សី ៤៣ប្រភេទ និងថនិកសត្វ ២ប្រភេទ។




ការពង្រឹងសមត្ថភាពឧទ្យានុរក្សតំបន់រ៉ាមសារស្ទឹងសែន



ការល្បាតប្រចាំខែរបស់ឧទ្យានុរក្សតំបន់រ៉ាមសារស្ទឹងសែន

## តំបន់រ៉ាមសារបឹងទន្លេឆ្មា

- **ការរៀបចំផែនការបែងចែក និងគ្រប់គ្រងតំបន់៖** អង្គការជីវិតធម្មជាតិនៅកម្ពុជាបានចូលរួមជាទៀងទាត់នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ខេត្ត
- **ការពង្រឹងសមត្ថភាពដល់មន្ត្រីឧទ្យានុរក្សរបស់រដ្ឋាភិបាល៖** អង្គការជីវិតធម្មជាតិនៅកម្ពុជា អាចរៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេស ជីភីអេស (GPS) និងសៀវភៅស្មាត (SMART Book) ដល់មន្ត្រីឧទ្យានុរក្សចំនួន ១២នាក់ នៅតំបន់រ៉ាមសារ បឹងទន្លេឆ្មា ដើម្បីរៀបចំមន្ត្រីឧទ្យានុរក្សសម្រាប់ល្បាតប្រចាំខែចាប់តាំងពីខែតុលា ឆ្នាំ ២០២១ ស្តីពីការអនុវត្តច្បាប់ និងការអង្កេតតាមដានជីវៈចម្រុះ ដោយលទ្ធផលខាងក្រោម៖
    - ចំនួនមន្ត្រីឧទ្យានុរក្ស៖ ១៥នាក់
    - ចំនួនល្បាត៖ ៦០លើក
    - ចំនួនថ្ងៃល្បាត៖ ៦០ថ្ងៃ
    - ចម្ងាយល្បាត៖ ២៤៣០គីឡូម៉ែត
    - ចំនួនម៉ោង៖ ៣៤២ម៉ោង
    - សកម្មភាពខុសច្បាប់ និងការអនុវត្តច្បាប់៖ ៤៩ករណី

- ចំនួនសត្វស្លាបៈ ២៨ក្បាល
- ចំនួនថនិកសត្វៈ ១ក្បាល។



ការល្បាតប្រចាំខែរបស់ឧទ្យានុរក្សតំបន់រ៉ាមសារបឹងទន្លេឆ្មា

## ២.៣ អភិរក្សសត្វស្លាបទេសន្តរប្រវេសន៍

- ផ្សព្វផ្សាយពីវាសត្វស្លាបទេសន្តរប្រវេសន៍ ឆ្នាំ២០២១ តាមបណ្តាញសង្គម ក្នុងគោលបំណងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋដល់កិច្ចការពារ និងអភិរក្សសត្វស្លាបទេសន្តប្រវេសន៍ដែលកំពុងរងគ្រោះដូចសត្វក្រៀលជាដើម។
- អង្គការជីវិតធម្មជាតិនៅកម្ពុជា បានចុះអង្កេតតាមដានសត្វចាបព្រៃវែង នៅក្នុងតំបន់ការពារទេសភាពបឹងព្រែកល្ពៅ។ លទ្ធផលនៃការតាមដានបឋមបង្ហាញថា បឹងព្រែកល្ពៅគឺប្រហែលជាទីតាំងសំខាន់តែមួយគត់សម្រាប់សត្វចាបព្រៃវែងក្នុងប្រទេសកម្ពុជា ឬឥណ្ឌូចិន។ នៅឆ្នាំ ២០២១ យើងបានសង្កេតឃើញសត្វចាបព្រៃវែង ចាប់ពីចុងខែធ្នូ ឆ្នាំ២០២០ ខណៈពេលដែលកំពុងធ្វើជំរឿនសត្វក្រៀល ដោយមានការប្រទះឃើញជាលើកដំបូងនៃវត្តមានសត្វចាបព្រៃវែងចំនួន ២០ក្បាល។ ជាបន្តបន្ទាប់ ក្រុមការងារយើងបានអង្កេតតាមដានជម្រករបស់សត្វចាបព្រៃវែងនេះ ដើម្បីពិនិត្យមើលអំពីបម្រែបម្រួលនៃចំនួនសត្វស្លាបនេះនៅនឹងទីតាំង ព្រមទាំងវាយតម្លៃគុណភាពឬស្ថានភាពទីតាំងជម្រករបស់សត្វស្លាបនេះ។ យើងបានរកឃើញថាចំនួនសត្វចាបព្រៃវែង បានកើនឡើង

ជារៀងរាល់ថ្ងៃ ដោយជាអតិបរមាមានចំនួន ២,៧៨០ ក្បាលនៅថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០២១។ គិតត្រឹមចុងខែមេសា មានសត្វចាបព្រៃវែងប្រហែល ១-៤ ក្បាលប៉ុណ្ណោះដែលត្រូវបានកត់ត្រាដោយចៃដន្យនៅមុខទីស្នាក់ការតំបន់ការពារទេសភាពបឹងព្រែកល្ពៅ។ អត្ថបទសិក្សាស្រាវជ្រាវត្រៀមសម្រាប់ដាក់បោះពុម្ព ដែលមានចំណងជើងថា"ភស្តុតាងលេចចេញបង្ហាញពីសារៈសំខាន់ជាសាកលនៃតំបន់ការពារទេសភាពបឹងព្រែកល្ពៅក្នុងប្រទេសកម្ពុជា សម្រាប់សត្វចាបព្រៃវែង ត្រូវបានដាក់ជូនទស្សនាវដ្តី Cambodia Journal of Natural History (CJNH) ដើម្បីបោះពុម្ពជាអត្ថបទសារខ្លី។



សត្វចាបព្រៃវែងជិតផុតបំផុតលើពិភពលោកមានវត្តមាននៅតំបន់ការពារទេសភាពបឹងព្រែកល្ពៅ

## ២.៤ លើកកម្ពស់ជីវភាព និងបង្កើនការចូលរួមពីប្រជាមូលដ្ឋានតំបន់ការពារទេសភាពអន្លង់ព្រីង

- ខណៈពេលដែលប្រជាជនកំពុងប្រឈមមុខនឹងបញ្ហាដោយសារតែការផ្ទុះឡើងនៃមេរោគកូវីដ១៩ អង្គការជីវិតធម្មជាតិនៅកម្ពុជា បានផ្តល់អំណោយ (អាហារ) ដល់សហគមន៍មូលដ្ឋានចំនួន២០០សហគមន៍ ដើម្បីគាំទ្រដល់ការចិញ្ចឹមជីវិតក្នុងតំបន់ និងលើកកម្ពស់សារៈសំខាន់នៃតំបន់ទេសភាពដីសើម។

- ក្រុមសន្សំប្រាក់ចំនួន៥ក្រុម ត្រូវបានបង្កើតឡើង និងដំណើរការដោយមានសមាជិកចំនួន ៧៨នាក់។ គម្រោងនេះនឹងជួយដល់ការចិញ្ចឹមជីវិតក្នុងស្រុកក្នុងអំឡុងពេលជំងឺរាតត្បាត កូវីដ១៩ ។
- ដើម្បីគ្រប់គ្រងកាកសំណល់ក្នុងជីវិតប្រចាំថ្ងៃ និងគាំទ្រការចិញ្ចឹមជីវិតរបស់ក្រុមអភិរក្សក្នុងស្រុក ក្រុមអាជីវកម្មកែឆ្នៃត្រូវបានបង្កើតឡើងនៅតំបន់ការពារទេសភាពអន្លង់ព្រីង។ អង្គការជីវិតធម្មជាតិនៅកម្ពុជា បានផ្តល់ដើមទុន និងសម្ភារៈ (រទេះ ម៉ូតូ) ដើម្បីទិញកាកសំណល់ប្រចាំថ្ងៃ ដែលអាចកែច្នៃឡើងវិញនៅក្នុងភូមិគោលដៅជុំវិញអន្លង់ព្រីង។
- **គំនិតផ្តួចផ្តើម ស្រូវមិត្តក្រៀល** នេះត្រូវបានដឹកនាំ និងអនុវត្តដោយ អង្គការជីវិតធម្មជាតិនៅកម្ពុជា ហើយសមិទ្ធិផលសំខាន់ៗក្នុងឆ្នាំ២០២១ រួមមាន៖
  - ទំហំដីស្រែដែលបានជួលសំរាប់អភិរក្សសត្វក្រៀលត្រូវបានពង្រីកពី ៨.៣៧ ហិចតា ក្នុងឆ្នាំ ២០២០ ដល់ ១៨.៤១ ហិចតា ក្នុងឆ្នាំ២០២១ ដោយជួលដីស្រែរបស់កសិករនៅក្បែរតំបន់ការពារទេសភាពអន្លង់ព្រីងសម្រាប់ការធ្វើស្រែសាកល្បងសម្រាប់ពង្រីកទីជម្រក និងបន្ថែមអាហារដល់សត្វក្រៀល។
  - ទិន្នផលស្រូវឆ្នាំ២០២១ សរុបប្រមាណ ៨,៧៣៧ គីឡូក្រាម (៨,៧៣៧ តោន) ពីពូជស្រូវពីរប្រភេទ (ស្រូវពេងលលក = ១,៥១២ គីឡូក្រាម និងស្រូវសំបកទទឹម = ៧,២២៥ គីឡូក្រាម)
  - ក្រុមអង្កេតតាមដានវាលស្រែសម្រាប់សត្វក្រៀល និងការអង្កេតតាមដានជីវចម្រុះផ្សេងៗត្រូវបានបង្កើតឡើង។
  - របាយការណ៍ត្រួតពិនិត្យឆ្នាំទី១ អំពីការពិសោធន៍ដាំស្រូវក្រៀលនៅតំបន់ការពារទេសភាពអន្លង់ព្រីងត្រូវបានរៀបចំឡើង។
  - សេចក្តីព្រាងចុងក្រោយនៃពិធីសារស្រូវមិត្តក្រៀល និងសហគមន៍ស្រូវមិត្តក្រៀលត្រូវបានរៀបចំឡើង។
  - កសិករសហការជាមួយគម្រោងស្រូវមិត្តក្រៀលចំនួន ៤១នាក់ បានទទួលគ្រាប់ពូជស្រូវ និងជីសរីរាង្គពីគម្រោង និងបានបញ្ចប់ការប្រមូលផលស្រូវចំនួន ៥៣តោន។
  - កសិករ២នាក់ ក្នុងចំណោម៤១នាក់ដែលសហការជាមួយគម្រោងមិនបានអនុវត្តតាមលក្ខណៈវិនិច្ឆ័យរបស់ស្រូវមិត្តក្រៀល។
  - គម្រោងរបស់យើងគាំទ្រការស្វែងរកទីផ្សារសម្រាប់កសិករដែលសហការជាមួយគម្រោង ហើយពួកគេអាចលក់ស្រូវក្នុងតម្លៃខ្ពស់ (ខ្ពស់ជាងទីផ្សារក្នុងស្រុក ៣ភាគរយ) ។
  - កសិករដែលសហការជាមួយគម្រោងទទួលបានវគ្គបណ្តុះបណ្តាលកសិកម្មទាំងអស់ ទោះបីជាមានការពន្យាពេលរយៈពេលខ្លី ដោយសារការរីករាលដាលនៃជំងឺកូវីដ១៩ក៏ដោយ។
  - ការប្រមូលទិន្នន័យសម្រាប់ការត្រួតពិនិត្យយោងទៅតាមឧបករណ៍ ព្រីសឹម(PRISM) ត្រូវបានបញ្ចប់រួចរាល់។
  - ស្រូវមិត្តក្រៀលត្រូវបានផ្សព្វផ្សាយនៅក្នុងពិព័រណ៍ទីផ្សារកសិករ។
  - ក្រុមការងារទីវាល និងមន្ត្រីឧទ្យានុរក្សបានធ្វើការអង្កេតតាមដានជាប្រចាំ ដើម្បីពិនិត្យលទ្ធភាពប្រើប្រាស់របស់សត្វក្រៀល នៅវាលស្រែរបស់សត្វក្រៀល។
  - បន្ទប់ស្តុកស្រូវត្រូវបានសាងសង់រួចរាល់នៅជាប់នឹងទីស្នាក់ការតំបន់ការពារទេសភាពអន្លង់ព្រីង។



ផ្តល់អំណោយដល់សហគមន៍មូលដ្ឋានចំនួន២០០សហគមន៍ ដើម្បីគាំទ្រដល់ការចិញ្ចឹមជីវិតក្នុងបរិបទកូវីដ១៩




ផ្តល់សំភារៈដល់សាលាបឋមសិក្សាដែលមានទីតាំងជុំវិញតំបន់ការពារទេសភាពអន្លង់ព្រីងដើម្បីការពារការរៀលដាល់នៃមេរោគកូវីដ១៩




គម្រោងសហគមន៍ស្រូវមិត្តក្រៀល






ទីតាំងសហគមន៍ស្រូវមិត្តក្រៀលនិងការផ្តល់ពូជស្រូវដល់កសិករ

## តំបន់រ៉ាមសារស្ទឹងសែន

**ការពង្រឹង សហគមន៍តំបន់ការពារធម្មជាតិទួលនាងសាវផ្លូវហ្លួងនិងការបង្កើត សហគមន៍តំបន់ការពារធម្មជាតិ ថ្មី**

- ដោយមានការជួយជ្រោមជ្រែងពី អង្គការជីវិតធម្មជាតិនៅកម្ពុជា សហគមន៍តំបន់ការពារធម្មជាតិ ដែលមានស្រាប់ សហគមន៍តំបន់ការពារធម្មជាតិទួលនាងសាវផ្លូវហ្លួង អាចដំណើរការម្តងទៀតចាប់តាំងពីការបង្កើតឡើងដំបូងក្នុងឆ្នាំ២០០៧ ហើយសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដែលរួមមានរចនាសម្ព័ន្ធ សហគមន៍តំបន់ការពារធម្មជាតិ ដែលត្រូវបានអភិវឌ្ឍជាមួយនឹងគណៈកម្មាធិការ និងសមាជិកថ្មីដែលត្រូវបានធ្វើវិសោធនកម្ម។ ដោយច្បាប់ ពិធីសារល្បាត ការពិគ្រោះយោបល់លើផែនការគ្រប់គ្រងនៅថ្នាក់ឃុំ និងអ្នកពាក់ព័ន្ធ និងពានរង្វាន់ថ្មីៗពីពីវេទិកា ក្រសួងបរិស្ថាន និង អង្គការក្រៅរដ្ឋាភិបាល ។ លើសពីនេះ ក្នុងឆ្នាំនេះសហគមន៍តំបន់ការពារធម្មជាតិទួលនាងសាវផ្លូវហ្លួង អាចបំពេញការល្បាតបានចំនួន ៤៨ ករណី បង្ក្រាបករណីខុសច្បាប់ចំនួន ៦២ ករណី និងកត់ត្រាប្រភេទសត្វស្លាបចំនួន ៣០ ប្រភេទ។
- អង្គការជីវិតធម្មជាតិកម្ពុជា បានជួយអ្នកភូមិទួលនាងសាវ ក្នុងដំណើរការស្នើសុំបង្កើត សហគមន៍តំបន់ការពារធម្មជាតិ ថ្មី ហៅ សហគមន៍តំបន់ការពារធម្មជាតិផ្សោត នៅតំបន់ស្ទឹងសែនរ៉ាមសារ។ នេះរួមមានការពិគ្រោះយោបល់នៅថ្នាក់ឃុំ ការពិនិត្យដី និងការកំណត់តំបន់ ការរៀបចំ និងការដាក់សំណើបង្កើត សហគមន៍តំបន់ការពារធម្មជាតិ ទៅសាលាស្រុក និងការពិគ្រោះយោបល់ជាមួយសាលាស្រុក និងមន្ទីរបរិស្ថានខេត្ត។





សហគមន៍តំបន់ការពារធម្មជាតិទួលនាងសាវផ្លូវហ្លួងធ្វើការល្បាតប្រចាំខែ

## សហគមន៍ព្រៃឈើភ្នំតន់តង់

- ចាប់ពីខែកញ្ញា ឆ្នាំ២០២១ អង្គការជីវិតធម្មជាតិកម្ពុជាបានគាំទ្រដល់ភូមិគណៈកម្មការចាស់ទុំមកពីភូមិចាន់ ឃុំតាវែងលើ ស្រុកតាវែង និងភូមិកាណាត ឃុំតាឡាវ ស្រុកអណ្តូងមាស ខេត្តរតនគីរី បានរួមគ្នាចុះល្បាតព្រៃសហគមន៍ភ្នំទុនតង់ដើម្បីសិក្សាពីសក្តានុពល និងជីវៈចម្រុះនៅក្នុងតំបន់។ ព្រៃសហគមន៍ភ្នំទុនតង់មានទីតាំងជាប់និងក្រុមហ៊ុនចំការកៅស៊ូក្រុងប៊ុកនិងមានសក្តានុពលសម្រាប់រៀបចំបង្កើតជាសហគមន៍ព្រៃឈើទុកសំរាប់កូនចៅជំនាន់ក្រោយប្រើប្រាស់ដោយនិរន្តភាព។

- អង្គការជីវិតធម្មជាតិកម្ពុជាបានគាំទ្រដល់គណៈកម្មការចាស់ទុំមកពីភូមិចាន់ដើម្បីរៀបចំបង្កើតសហគមន៍ភ្នំទុនតង់។ ដំណើរការនេះត្រូវបានគាំទ្រពីរដ្ឋបាលព្រៃឈើនិងអាជ្ញាធរមូលដ្ឋាននៃឃុំតាវែងលើ ស្រុកតាវែង ខេត្តរតនគីរី។



កិច្ចប្រជុំជាមួយរដ្ឋបាលស្រុកតាវែងនិងស្រុកអណ្តូងមាសរតនគិរី



ការល្បាតប្រចាំខែរបស់គណៈកម្មការចាស់ទុំមកពីភូមិចាន់

## ២.៥ កសាងសមត្ថភាព

- អង្គការជីវិតសត្វស្លាបអន្តរជាតិកម្មវិធីនៅកម្ពុជា បានផ្ទេរទ្រព្យសម្បត្តិ និងបុគ្គលិកទាំងស្រុងទៅឲ្យ អង្គការជីវិតធម្មជាតិនៅកម្ពុជា នៅចុងថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២១។
- អង្គការជីវិតសត្វស្លាបអន្តរជាតិកម្មវិធីនៅកម្ពុជា កំពុងដំណើរការផ្ទេរគម្រោងរបស់ពួកគេទៅ អង្គការជីវិតធម្មជាតិនៅកម្ពុជា។
- បុគ្គលិករបស់ អង្គការជីវិតធម្មជាតិកម្ពុជា ត្រូវបានបង្កើនពី ៦នាក់ ដល់ ២៣នាក់។

• ទម្រង់នៃ អង្គការជីវិតធម្មជាតិកម្ពុជា ត្រូវបាននិងកំពុងកែលម្អ និងទទួលបាននូវជំនួយដ៏ធំពីម្ចាស់ជំនួយធំៗ ដូចជា មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីទទួលរងការគំរាមកំហែង(Critical Ecosystem Partnership Fund), អង្គការអុកហ្វាម(Oxfam), សហភាពអឺរ៉ុប(European Union)។

• អង្គការជីវិតធម្មជាតិនៅកម្ពុជា បានចាប់ផ្តើមធ្វើការនៅតំបន់រ៉ាមសារបឹងទន្លេឆ្មា ក្នុងខែកញ្ញា ជាមួយនឹងមូលនិធិពីសហភាពអឺរ៉ុប។

• គណៈកម្មាធិការប្រតិបត្តិនៃ អង្គការជីវិតធម្មជាតិនៅកម្ពុជា បានរៀបចំកិច្ចប្រជុំតាមការគ្រោងទុកក្នុងកំឡុងឆ្នាំ ២០២១ ដើម្បីធានាបាននូវប្រតិបត្តិការរបស់អង្គការនេះ។

• អង្គការជីវិតធម្មជាតិនៅកម្ពុជា បានក្លាយជាអ្នកសម្របសម្រួលក្រុមការងារអភិរក្សសត្វត្មាតកម្ពុជា និងជាដៃគូគម្រោងរបស់ Save Asian Vulture from Extinction (SAVE)។



បុគ្គលិកអង្គការជីវិតធម្មជាតិកម្ពុជាគម្រោងទន្លេសាបយើងទើបចាប់ផ្តើមក្នុងឆ្នាំ២០២១



កិច្ចប្រជុំគណៈកម្មការផ្ទេរទ្រព្យសម្បត្តិ និងបុគ្គលិក



កិច្ចប្រជុំបុគ្គលិករបស់អង្គការ

## ៣. របាយការណ៍ហិរញ្ញវត្ថុ

### របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២១

| | 2021 |
|---|---|
| | US$ |
| **ចំណូល** | |
| ចំណូលទទួលបានពីម្ចាស់ជំនួយ | 390,088.11 |
| វិភាគទានពីម្ចាស់ជំនួយឯកជន | 0 |
| ចំណូលផ្សេងៗ | 7,117.28 |
| **សរុបចំណូល** | **397,205.39** |
| **ចំណាយ** | |
| ចំណាយលើបុគ្គលិក | 83,647.57 |
| សម្ភារៈការិយាល័យ/សម្ភារៈ/ឧបករណ៍ប្រើប្រាស់ | 485.14 |
| ទូរគមនាគមន៍ / ប៉ុស្តិ៍ / អ៊ិនធឺណិត | 1,217.52 |
| ការងារអភិរក្ស និងសហគមន៍ | 89,309.30 |
| សិក្ខាសាលា / កិច្ចប្រជុំ | 10,178.28 |
| ឧបករណ៍និងសម្ភារៈផ្គត់ផ្គង់ | 22,050.88 |
| ការធ្វើដំណើរ | 7,474.05 |
| សាវនកម្ម | 1,110.00 |
| ការផ្តល់ជំនួយបន្ត | 25,575.70 |
| ចំណាយប្រយោល | 1,648.32 |
| **សរុបចំណាយ** | **242,696.76** |
| **ការទូទាត់ចំណូល និងចំណាយ** | **154,509** |
| **សមតុល្យពីឆ្នាំមុន** | **56,474** |
| **សមតុល្យបំណាច់ឆ្នាំ២០២១** | **210,982.26** |

## ៤. ដៃគូ និងម្ចាស់ជំនួយ

### ស្ថាប័នរដ្ឋ

### អង្គការដៃគូ និងក្រុមការងារ

BirdLife INTERNATIONAL CAMBODIA PROGRAMME

WWT

WCS

ក្រុមការងារអភិរក្សសត្វត្មាតកម្ពុជា CAMBODIA VULTURE WORKING GROUP

### ម្ចាស់ជំនួយ

DARWIN INITIATIVE

CRITICAL ECOSYSTEM PARTNERSHIP FUND

Funded by the European Union

OXFAM

KNCF

IUCN National Committee of The Netherlands

BANYAN TREE GLOBAL FOUNDATION

CONSERVATION LEADERSHIP PROGRAMME

Oriental BIRD CLUB

FONDATION SEGRÉ

BirdLife INTERNATIONAL



**អង្គការជីវិតធម្មជាតិនៅកម្ពុជា/NatureLife Cambodia**
រតនគិរី៖ ផ្ទះលេខ៣៥ ផ្លូវលេខ៣៣ ភូមិអូរកន្ទិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី
ភ្នំពេញ៖ ផ្ទះលេខ៣២A សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ
អ៊ីម៉ែល៖ admin@naturelifecambodia.org
គេហទំព័រ ៖ www.naturelifecambodia.org
Facebook: facebook.com/NatureLifeCambodia
លេខទំនាក់ទំនង៖ ០៧៨ ៧៣២ ២៤០ ឬ ០២៣ ៩៩៣ ៦៣១